# និរន្តរភាពវិស័យជលផលនៅក្នុងបឹងទន្លេសាប

## FHI 360/Global FISH Alliance

ព្រឹត្តិប័ត្រប្រចាំ ខែមិថុនា ឆ្នាំ២០១៣

## សិក្ខាសាលាសហគមន៍នេសាទ បង្ហាញពីភាពជោគជ័យនៃការងារអភិរក្សបឹង

ខេត្តបាត់ដំបង - សហគមន៍នេសាទ (CFi) នៅខេត្តបាត់ដំបង ដោយមានការគាំទ្រពីអង្គការក្រុមទ្រទ្រង់ភូមិ (VSG) ដែលជាអង្គការមិនរកប្រាក់ចំណេញនិងមិនមែនរដ្ឋាភិបាល បានបង្កើតក្នុងសិក្ខាសាលាមួយ ដែលជាពេលផ្តល់ឱកាសដល់ប្រជានេសាទ ដើម្បីជួបជាមួយនាយខ័ណ្ឌរដ្ឋបាលជលផលបាត់ដំបង និងលោកអភិបាលខេត្តបាត់ដំបង។ ហើយវេទិកានេះក៏បានផ្តល់ឱកាសសម្រាប់ រាជរដ្ឋាភិបាល អង្គការ និងប្រជានេសាទ ដើម្បីទស្សនាបឹងរាំងពែនបីត និងដាំដើមឈើទុកជាអនុស្សាវរីយ៍។

សិក្ខាសាលានេះមានគោលបំណងដើម្បីបង្ហាញប្រជានេសាទ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ពីសារៈសំខាន់នៃធនធានធម្មជាតិ និងសាមគ្គីភាពរវាងសមាជិកសហគមន៍ អ្នកភូមិអង្គការក្រៅរដ្ឋាភិបាល និងរដ្ឋាភិបាល។ សហគមន៍នេសាទនៅខេត្តបាត់ដំបង បានស្នើរសុំឲ្យមានការរួមចំណែក និងការគាំទ្រពីអ្នកភូមិ អង្គការក្រៅរដ្ឋាភិបាល និងរដ្ឋាភិបាល ក្នុងការការពារធនធានធម្មជាតិទាំងអស់គ្នា។

កម្មវិធីនេះទទួលបានកិត្តិយសដោយមានវត្តមានឯកឧត្តម ជាម ចាន់សុភ័ណ អភិបាលរងខេត្តបាត់ដំបងអញ្ជើញចូលរួម ជាមួយប្រជាជនប្រមាណជា200នាក់។ ឯកឧត្តមអភិបាលរងខេត្ត បានណែនាំអ្នកភូមិក្នុងកំឡុងពេលសិក្ខាសាលាថាធនធានធម្មជាតិគឺមានសារៈសំខាន់ណាស់សម្រាប់ប្រជាជនគ្រប់រូប។ គាត់បានមានប្រសាសន៍ទៀតថារាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា បានយកចិត្តទុកដាក់បន្ថែមទៀតដើម្បីការពារធនធានធម្មជាតិនិងជីវភាពរបស់ប្រជាជន។

ចាប់តាំងពីឆ្នាំ 2007 មក បឹងរាំងពែនបីត ត្រូវបានរក្សាទុកជាបឹងអភិរក្សមួយ ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគមន៍នេសាទស្ពឺក្រោមរហាលសួង។ តំបន់អភិរក្សនេះមានចំនួន1390ហិកតាដែលក្នុងនោះ 80ហិកតាជាតំបន់ព្រៃលិចទឹក។

សហគមន៍នេសាទខេត្តបាត់ដំបង បានរៀបចំសកម្មភាពល្បែត និងចូលរួមចំនែកសកម្មភាពសង្គម ដោយទទួលបានកញ្ចប់ថវិកាពី មូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី អង្គការ OXFAM និង ForumSyd តាមរយៈអង្គការ VSG និងជាមួយការរួមចំណែករបស់អ្នកភូមិ។ សកម្មភាពមួយក្នុងចំនោមសកម្មភាពទាំងមូល គឺសង់ផ្លូវឡើងវិញពីភូមិទៅបឹងអភិរក្សដើម្បីជួយដល់ប្រជាជននៅក្នុងសហគមន៍។

លោក ហោ សំអាត អនុប្រធាននៃ សហគមន៍នេសាទរហាលសួងស្ពឺក្រោមបានឱ្យដឹងថា "យើងសង្ឃឹមថាការធ្វើសិក្ខាសាលានេះគឺអាចបង្ហាញសហគមន៍ផ្សេងៗទៀតអ្នកភូមិ ប្រជានេសាទ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ពីសមិទ្ធិផលរបស់យើងនិងធនធានធម្មជាតិមួយដែលយើងកំពុងធ្វើការយ៉ាងពិតជាពិបាកក្នុងការការពារ។" លោកបានបន្តថា "យើងធ្វើវាដោយសារតែយើងគិតដល់ប្រជាជនគ្រប់រូប ពួកគាត់នឹងអាចទទួលបានអត្ថប្រយោជន៍។ ក្នុងអំឡុងពេលរដូវវស្សាត្រីនឹងផ្លាស់ទីទៅទន្លេនិងវាលស្រែ ដែលប្រជាជនអាចនេសាទត្រីបាន ហើយព្រៃលិចទឹកនេះអាចជួយកាត់បន្ថយផលប៉ះពាល់មួយចំនួនដែលបណ្តាលមកពី ការផ្លាស់ប្តូរអាកាសធាតុ។"

*ព័ត៌មានបន្ថែមទាក់ទិននឹងការងារនេះសូមទាក់ទង លោក ហោ សំអាត អនុប្រធានសហគមន៍នេសាទស្ពឺក្រោមរហាលសួង។*

#11, Street 302, Boeung Keng Kang I,
Khan Chamkamon, Phnom Penh

E-mail: gfishalliancecambodia@gmail.com
Tel: (855)89 555 313

# គំរោងគុណភាព និងសុវត្ថិភាពរបស់ត្រី និងផលិតផលត្រីកែច្នៃ

គំរោងគុណភាព និងសុវត្ថិភាពរបស់ត្រី និងផលិតផលត្រីកែច្នៃដើម្បីបង្កើនការធ្វើពាណិជ្ជកម្មត្រី នៅកម្ពុជា ត្រូវបានឧបត្ថម្ភដោយ សហគមន៍អឺរ៉ុប DANIDA និងដៃគូអភិវឌ្ឍន៍ដទៃទៀត។ គំរោងនេះត្រូវបានអនុវត្តដោយក្រសួងពាណិជ្ជកម្ម។

គំរោងនេះមានគោលបំណង ដើម្បីពង្រឹងការធ្វើពាណិជ្ជកម្មត្រីនៅកម្ពុជា តាមរយៈការបង្កើនសមត្ថភាព ពង្រឹងសមត្ថភាពប្រជាជនដែលទាក់ទងនឹងកិច្ចការងារបន្ទាប់ពីនេសាទរួចរាល់ហើយ អោយពួកគាត់មានលទ្ធភាពរក្សាគុណភាពបានល្អ រក្សាតំលៃរបស់ផលិតផលត្រីកែច្នៃ។ គំរោងនេះក៏ជួយផ្តល់លទ្ធភាព និងមធ្យោបាយទាក់ទងជាមួយទីផ្សារក្នុងស្រុកនិងក្រៅស្រុកផងដែរ។

អង្គការសហប្រជាជាតិអង្គការអភិវឌ្ឍន៍ឧស្សាហកម្ម(UNIDO) បានចុះកិច្ចសន្យាដើម្បីធ្វើការជាមួយរដ្ឋបាលជលផល(FiA) នាយកដ្ឋានជលផលនៃបច្ចេកវិទ្យា ការប្រមូលផលនិងត្រួតពិនិត្យគុណភាព នៅក្នុងខេត្តកំពង់ធំ និងខេត្តពោធិ៍សាត់ ដែលជាកន្លែងដ៏ធំនៃការកែច្នៃផលិតផលត្រី កំពុងតែចាប់ផ្តើមដំណើរការ។ កន្លែងកែច្នៃផលិតផលត្រីនេះគឺផ្តោត លើការធ្វើត្រីងៀត ត្រីឆ្អើរ និងប្រហុក។

គំរោងនេះនឹងសំរេចបាននូវលទ្ធផលទាំងប្រាំះ

1. លទ្ធផលទី1គឺះ ការវាយតំលៃលើគុណភាពបច្ចុប្បន្ន ដែលផ្តោតលើសុវត្ថិភាព បន្ទាប់ពីនេសាទរួចរាល់ហើយ។ សកម្មភាពទាំងនេះ គឺទាក់ទងទៅនឹងការពិនិត្យឡើងវិញចំពោះការផលិត ការហាល និងការផ្ទុក។ ការប្រត្តិបត្តិលើសុវត្ថិភាពចំណីអាហារ ការវាយតំលៃលើហានិភ័យនានា ហើយផ្តល់ជាអនុសាសន៍ក្នុងការផ្លាស់ប្តូររបៀបរបបមួយចំនួនដើម្បីពង្រឹងគុណភាព និងសុវត្ថិភាព។
2. លទ្ធផលទី2គឺះ បង្កើនការយល់ដឹងដល់អ្នកនេសាទ អ្នកផលិតត្រី និងអ្នកជំនួញ អំពីគុណភាពនិងសុវត្ថិភាពដើម្បីធានាអោយបាននូវកំរិតស្តង់ដា។ លទ្ធផលទាំងនេះនឹងរួមបញ្ចូលតាមរយៈសកម្មភាព វគ្គបណ្តុះបណ្តាលយុទ្ធនាការលើកកំពស់ការយល់ដឹងនានា និងការវាយតំលៃអំពីកំរិតយល់ដឹងក្នុងពេលបច្ចុប្បន្ន ។
3. លទ្ធផលទី3គឺះ បង្កើតសមាគមន៍សហប្រតិបត្តិការណ៍ផលិតផលត្រីកែច្នៃ។ ដើម្បីការបង្កើតសមាគមន៍សហប្រតិបត្តិការណ៍ផលិតផលត្រីកែច្នៃអោយបានសំរេច ត្រូវមានការកំនត់អោយច្បាស់លាស់ ពីក្រុមគោលដៅទាំងនេះ និងតំបន់ដែលមានសក្តានុពល។ សកម្មភាពមួយចំនួននឹងត្រូវដាក់ជាយុទ្ធសាស្រ្តដូចជាការផ្តល់ប្រឹក្សាផ្នែកច្បាប់ និងលក្ខន្តិកៈក្នុងការបង្កើតសមាគមន៍តាមរយៈការចូលរួម និងផ្តល់ប្រឹក្សានានា ក្នុងការសំរេចចិត្ត។ សមាគមន៍សហប្រតិបត្តិការណ៍ផលិតផលត្រីកែច្នៃ នឹងត្រូវបានផ្តល់នូវការត្រួតពិនិត្យ និងការគ្រប់គ្រងឲ្យសមស្របទៅតាមតំរូវការថ្នាក់ជាតិ និងអន្តរជាតិ។
4. លទ្ធផលទី4គឺះ ផ្តល់ជូននូវសេចក្តីណែនាំ និងបទដ្ឋានបច្ចេកទេសដែលចាំបាច់ និងបច្ចេកវិទ្យាដែលសមស្របដើម្បីទំនុកបំរុងសមាគមន៍សហប្រតិបត្តិការណ៍ផលិតផលត្រីកែច្នៃ។ លទ្ធផលទាំងនេះសម្រេចតាមរយៈការបង្កើតសេចក្តីណែនាំ ទាក់ទងការអនុវត្តការកែច្នៃត្រីឲ្យបានល្អ ការអនុវត្តអនាម័យ ការអនុវត្តវិធីគ្រប់គ្រងល្អ ការអនុវត្តការត្រួតពិនិត្យនិងវិភាគលើសារធាតុគ្រោះថ្នាក់មួយចំនួន បទដ្ឋានផលិតផល និងការបង្កើតនូវប្រព័ន្ធគ្រប់គ្រងមួយដែលអាចកត់ត្រាទុកនូវផលិតផលនានា។ បច្ចេកវិទ្យាសមស្របមួយសំរាប់ផ្តល់តំលៃបន្ថែមទៀតដល់ផលិតផល និងខ្សែចង្វាក់ផលិតភាពរបស់ទីផ្សាផ្គត់ផ្គង់នឹងត្រូវកំនត់ជាមួយគ្នានឹងការណែនាំដល់ភាគីដែលពាក់ព័ន្ធ។
5. លទ្ធផលទី5គឺះ បង្កើតអោយមាននូវគំរូមួយនៃបទអន្តរាគមន៍សំរាប់អោយផលិតផលដែលមានគុណភាពនិងសុវត្ថិភាព។ លទ្ធផលទាំងនេះអាចសំរេចបានតាមរយៈការកំនត់គោលដៅផលិតផល និងសោភ័ណភាព

តាមរយៈការផ្តល់នូវឧបករណ៍ជាមូលដ្ឋានមួយចំនួនដើម្បីគាំទ្រក្នុងសកម្មភាពនេះ តាមរយៈការផ្តល់នូវវគ្គបណ្តុះបណ្តាល និងទស្សនៈកិច្ចសិក្សាដើម្បីគាំទ្រដល់សម្មភាពនេះ។ ហើយលើសពីនេះទៅទៀតដើម្បីសំរេចបាននូវលទ្ធផលនេះ គឺត្រូវផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសដល់អ្នកដែលអនុវត្តនូវគំរោងសាកល្បងមួយ។

UNIDO នឹងធ្វើការជាដៃគូរជាមួយអ្នកផលិតមួយចំនួន ដើម្បីអនុវត្តនូវគំរោងសកម្មភាព ក្នុងគោលបំណងបង្កើតនូវគំរោងគំរូមួយដល់វិស័យផលិតត្រីកែច្នៃ ។ ដោយក្តីរំពឹងថាគំរោងនេះនឹងធ្វើឲ្យវារីវប្បកម្មមានភាពប្រសើរឡើង និងប្រមូលទាំងអ្នកផលិត ទាំងពាណិជ្ជករ អោយរួបរួមគ្នាប្រកបរបរប្រកបដោយវិជ្ជាជីវៈ។ ដោយក្តីរំពឹងថាគំរោងនេះនឹងបង្កើតអោយមានចលនានានា ដើម្បីផ្តល់គុណប្រយោជន៍ដល់ អ្នកផលិតក៏ដូចជាពាណិជ្ជករសំរាប់រយៈពេលយូរអង្វែង។

ជាគោលដៅចំបងរបស់គំរោង UNIDO ផ្តោតលើទីផ្សារក្នុងស្រុក ភ្ជាប់នឹងគោលដៅរយៈពេលយូអង្វែងគឺឈានទៅរកទីផ្សារអន្តរជាតិ ជាពិសេសគឺទីផ្សារសហាគមន៍អឺរុប។

*ព័ត៌មានបន្ថែមទាក់ទិននឹងការងារនេះសូមចូលទៅគេហទំព័រ* office.cambodia@unido.org *។*

## សន្និសីទថ្នាក់ជាតិ

បន្ទាយមានជ័យ--សន្និសីទថ្នាក់ជាតិស្តីពី " វឌ្ឍនភាពនៃការគ្រប់គ្រងធនធានជលផល តាម រយៈ សហគមន៍នេសាទ បន្ទាប់ពីកំណែទម្រង់ស៊ីជម្រៅលើវិស័យជលផល និង ទិសដៅបន្ត" ត្រូវបានរៀបចំនឹងគាំទ្រថវិកាដោយ រដ្ឋបាលជលផល អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល(FACT) សម្ព័ន្ធប្រជានេសាទកម្ពុជា ForumSyd, មូលនិធិ McKnight, សហភាពអ៊ឺរ៉ុប សហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ(IUCN) សម្ព័ន្ធត្រីពិភពលោក(G-FISH)។ សន្និសីទនេះបានរៀបចំនៅថ្ងៃទី30 ខែ ឧសភា ឆ្នាំ2013 នៅសហគមន៍នេសាទ ភៀ្សកោះពងសត្វ ខេត្តបន្ទាយមានជ័យ។

គោលបំណងនៃសន្និសីទនេះគឺមានមានៈ

1. ដើម្បីស្វែងយល់អំពីវិឌ្ឍនភាព បញ្ហាប្រឈមដែលសហគមន៍នេសាទបានអនុវត្ត និងជួបប្រទះក្នុងការគ្រប់គ្រងធនធានជលផល បន្ទាប់ពីកំណែទម្រង់ស៊ីជម្រៅនៅលើវិស័យជលផល។
2. ផ្តល់ឱកាសដល់តំណាងសហគមន៍នេសាទ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានាធ្វើការចែករំលែកនូវមេរៀនជាបទពិសោធន៍ និងលើកឡើងនូវតម្រូវការ សំណូមពរចាំបាច់នានា ចូលរួមធ្វើការដោះស្រាយនូវបញ្ហាប្រឈមដែលជួបប្រទះ ដើម្បីពង្រឹងនូវសិទ្ធិអំណាច និងភាពជាម្ចាស់ក្នុងការគ្រប់គ្រងធនធានជលផលដែលរាជរដ្ឋាភិបាលបានប្រគល់ឱ្យ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។
3. ពង្រឹងនូវកិច្ចសហការ និងការគាំទ្រឱ្យបានខ្លាំងក្លាថែមទៀត ពីភាគីពាក់ព័ន្ធដល់ដំណើរការសហគមន៍នេសាទនៅទូទាំងប្រទេស ដើម្បីរួមចំណែជម្រុញការអនុវត្តគោលនយោបាយកំណែទម្រង់វិស័យជលផលរបស់រាជរដ្ឋាភិបាល ឱ្យទទួលបានជោគជ័យ។
4. ឯកឧត្តម ណៅ ធូក ប្រធានរដ្ឋបាលជលផលបានឱ្យដឹងថា "គោលបំណងនៃការធ្វើសន្និសីទនៅក្នុងសហគមន៍នេះ គឺដើម្បីបង្ហាញពីម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធទាំងអស់ពីសមិទ្ធិផលដែល រដ្ឋបាលជលផល អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍បានទទួលជោគជ័យនៅក្នុងតំបន់នេះ។"

សន្និសីទកាមមកពីសហគមន៍ ជលផលបានផ្តល់បទបង្ហាញអំពីសកម្មភាពសមិទ្ធិផលរបស់ពួកគេនិងបញ្ហាប្រឈមដល់ អ្នកចូលរួមជា ម្ចាស់ជំនួយ ជាដៃគូ និងជារដ្ឋាភិបាល បន្ទាប់ពីការថ្លែងសុន្ទរកថាខ្លីៗពីឯកឧត្តម ណៅ ធូក និងលោក ឱម សុវាត្ថរួចមក ។

នៅក្នុងសេចក្តីបញ្ចប់នៃការធ្វើបទបង្ហាញរបស់សហគមន៍នេសាទនិមួយៗ វេទិការសំណួរនិងចម្លើយ ដែលជាពេលដែលអនុញ្ញាតឱ្យ អ្នកចូលរួមក្នុងឱកាសនេះ សួរសំណួរទាក់ទិននឹងការ ធ្វើបទបង្ហាញរបស់ពួកគេ។ ក្នុងអំឡុងពេលនេះ

ឯកឧត្តម ណៅ ធូក មានប្រសាសន៍ថា "រដ្ឋបាលជលផលសប្បាយរីករាយនៅពេលដែលឃើញសមិទ្ធិផលដែលប្រជានេសាទ នៅក្នុងសហគមន៍បានធ្វើមកទល់និងពេលនេះ។ រដ្ឋបាលជលផលសប្បាយរីករាយក្នុងការផ្តល់តំបន់អភិរក្សបន្ថែមទៀតដើម្បីឲ្យសហគមន៍និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីការពារប្រសិនបើពួកគេចង់។" ឯកឧត្តមបានបន្តទៀតថា: "យើងកំពុងធ្វើការដើម្បីការពារធនធានធម្មជាតិរបស់យើងទាំងអស់គ្នា" ។

បន្ទាប់ពីការរាយការណ៍របស់ឯកឧត្តម ណៅ ធូក ស្តីអំពីលទ្ធផលនៃកិច្ចពិភាក្សារួចមក ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានសម្តែងការកោតសរសើរសម្រាប់ប្រធានបទដែលត្រូវបានពិភាក្សា។ ក្នុងអំឡុងពេលទស្សនកិច្ចនេះដែរ ឯកឧត្តម យឹម ឆៃលី ក៏បានទៅទស្សនាបឹងអភិរក្សសហគមន៍ មើលការតាំងពិព័រណ៍រូបថតនៃសកម្មភាពរបស់ សម្ព័ន្ធប្រជានេសាទកម្ពុជា និងសហគមន៍នេសាទ ព្រមទាំងផ្តល់ឱ្យនូវវិញ្ញាបនប័ត្រដល់សមាជិកសហគមន៍នេសាទដែលឆ្នើម។

*ព័ត៌មានបន្ថែមទាក់ទិននឹងការងារនេះសូមទាក់ទងលោកស្រី នូ វ៉ាន់សាន មន្ត្រីសម្របសម្រួលផ្នែកទំនាក់ទំនងនិងប្រព័ន្ធផ្សព្វផ្សាយរបស់អង្គការ G-FISH ។*

## វេទិការស្តីពី ឧបករណ៍នេសាទ និង ច្បាប់ជលផល

វេទិការស្តីពី ឧករណ៍នេសាទ និងច្បាប់ជលផលត្រូវបានធ្វើឡើងដោយមានមន្ត្រីជំនាញលោក សំ សត្យា ដែលមកពីរដ្ឋបាលជលផល បានធ្វើបង្ហាញដល់សមាជិកសហគមន៍នេសាទ និងអ្នកភូមិ នៅភូមិដូនទ្រី ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០១៣ ។

គោលបំណងនៃវេទិការនេះ គឺដើម្បីអញ្ជើញមន្ត្រីជំនាញផ្នែកជលផល មកធ្វើការណែនាំពីច្បាប់ជលផល និងឧបករណ៍នេសាទបែបលក្ខណ:គ្រួសារ ដើម្បីការពារធនធានជលផល។

លោក ជួង សុភា នាយខណ្ឌជលផលបាត់ដំបង បានចែករំលែកព័ត៌មានពីការប្រើប្រាស់ ឧបករណ៍នេសាទដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទអនុញ្ញាតឲ្យប្រើប្រាស់ជាលក្ខណ:គ្រួសារ។ លោក ជួង សុភា បានពន្យល់បន្ថែមពីភាពខុសគ្នារវាងឧបករណ៍នេសាទលក្ខណ:គ្រួសារ និង ការនេសាទជាលក្ខណ:ឧស្សាហកម្ម និង សិប្បកម្មដែលមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់បន្តទៀតទេ។ បច្ចុប្បន្ននេះនៅក្នុងឡូត៍នេសាទ៧ ក៏ដូចជាតំបន់ផ្សេងៗទៀតនៅក្នុងបឹងទន្លេសាប ដែលរដ្ឋាភិបាលបានអនុញ្ញាតឲ្យប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណ:គ្រួសារ។ លោក ជួង សុភា បានពន្យល់បន្តរទៀតពីការកំណត់នៃការប្រើ ប្រាស់ឧបករណ៍នេសាទជាលក្ខណ:គ្រួសារ នៅក្នុងដែនអភិរក្សនៅរដូវបើកនេសាទ ដែលមានចំនួន ៥០ប្រភេទ និងការប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណ:គ្រួសារក្នុងរដូវបិទនេសាទមានចំនួន ៤៤ ប្រភេទ ។

លោក សំ សត្យា អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល និងនិតិកម្ម បាននិយាយថាជនដែលប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ដូចជា អួនស្បៃមុង ឧបករណ៍ឆក់ ការបូមបាច និងការកាប់បំផ្លាញព្រៃលិចទឹកត្រូវទទួលទោស។ ជនណាដែលបានចូលរួមសកម្មភាពនេសាទល្មើសច្បាប់ត្រូវមានទោសជាប់ពន្ធនាគារ និងត្រូវបង់ប្រាក់ពិន័យ។ លោកបាននិយាយបន្តទៀតថា ប្រសិនបើសហគមន៍បានឃើញនូវសកម្មភាពបទល្មើសឆក់ត្រី ក៏ដូចជាការបំផ្លាញព្រៃឈើនោះ ពួកគាត់ត្រូវទៅរាយការណ៍ពីសកម្មភាពល្មើសដល់អាជ្ញាធរ ដើម្បីចុះបង្រ្កាបនិងបញ្ជូនជនល្មើសទៅតុលាការ។

ចុងបញ្ចប់នៃការធ្វើបទបង្ហាញនេះ អ្នកចូលរួមមានឪកាសសួរទៅអ្នកជំនាញផងដែលទាក់ទងទៅនឹងឧបករណ៍នេសាទខុសច្បាប់។ មានសំនួរល្អៗជាច្រើនដែលអ្នកចូលរួមបានសួរ ហើយពួកគាត់មានភាពសប្បាយរីករាយជាខ្លាំងដោយទទួលបានការចែករំលែកព័ត៌មានទាំងនេះ ហើយពួកគាត់ក៏សង្ឃឹមថាកម្មវិធីនេះនឹងមានម្តងទៀតនៅក្នុងតំបន់របស់ពួកគាត់។

*ព័ត៌មានបន្ថែមទាក់ទិននឹងការងារនេះសូមទាក់ទងលោកស្រី នូ វ៉ាន់សាន មន្ត្រីសម្របសម្រួលផ្នែកទំនាក់ទំនងនិងប្រព័ន្ធផ្សព្វផ្សាយរបស់អង្គការ G-FISH ។*

#11, Street 302, Boeung Keng Kang I,
Khan Chamkamon, Phnom Penh
E-mail: gfishalliancecambodia@gmail.com
Tel: (855)89 555 313